ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ...១៨៣៥៥...អពដ

សារលិខិតអបអរសាទរ

សូមគោរពជូន
ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យ៉ៃប
អនុប្រធានទី១ នៃរដ្ឋសភា

តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារ ខ្ញុំសូមសម្តែងនូវអំណរសាទរយ៉ាងក្លៀវក្លាប្រកបដោយមនោសញ្ចេតនារំភើបរីករាយ និងកក់ក្តៅបំផុត ក្នុងឱកាសដែល **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត** ត្រូវបានរដ្ឋសភា នីតិកាលទី៦ ផ្តល់សេចក្តីទុកចិត្តបោះឆ្នោតជ្រើសតាំងជា **អនុប្រធានទី១ នៃរដ្ឋសភា**។

ការទទួលបាននូវតួនាទីភារកិច្ចដ៏ឧត្តុង្គឧត្តមនាពេលនេះ គឺពិតជាស័ក្តិសមបំផុតចំពោះវីរភាពដ៏ថ្លៃថ្លារបស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត** ដែលជាថ្នាក់ដឹកនាំដ៏ឆ្នើមមួយរូបរបស់ប្រជាពលរដ្ឋកម្ពុជា ដោយបានយកអស់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតីពុះពារជំនះឧបសគ្គគ្រប់បែបយ៉ាង ដើម្បីចូលរួមក្នុងការជំរុញសេដ្ឋកិច្ចកម្ពុជាឱ្យមានកំណើនឡើង ក៏ដូចជាការចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការស្តារនិងអភិវឌ្ឍន៍ប្រទេសជាតិ ឱ្យសម្រេចបាននូវសុខសន្តិភាព ស្ថិរភាពសង្គម ស្ថិរភាពនយោបាយ និងភាពរីកចម្រើនលើគ្រប់វិស័យ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ស្ថិតក្នុងឱកាសប្រកបដោយមហាកិត្តិយសនេះ ខ្ញុំសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា គុណបុណ្យព្រះរតនត្រ័យកែវទាំងបី ទេវតាថែរក្សាឆ្នាំថ្មី សូមព្រះអង្គតាមជួយអភិបាលរក្សា ប្រោះប្រទានសព្វសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរ ជូនចំពោះ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត** និង **លោកជំទាវ** ព្រមទាំងក្រុមគ្រួសារជាទីស្រឡាញ់របស់ឯកឧត្តម សូមមានសុខភាពល្អបរិបូរណ៌ ពលានុភាពមាំមួន ជន្មាយុយឺនយូរ និងសូមសមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យ៉ៃប អនុប្រធានទី១ នៃរដ្ឋសភា** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

ថ្ងៃ ពុធ ១៧រោច ខែ ភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២០២១

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ

គង់ ឥន្ទ្រា

អាគារកែងមហាវិថី សហព័ន្ធរុស្សី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh